00893590

E270/1/Corr-1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| កែលើឯកសារលេខ៖ | ERN(s): | កាលបរិច្ឆេទ៖ | ប្រភេទកំណែ៖ |
|---|---|---|---|
| E270/1 | 00893580-00893583 | 15/03/2013 | ☒ កែលើឯកសារដើម<br>☐ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

| មូលហេតុនៃការកែតម្រូវ៖ |
|---|
| កែតម្រូវកាលបរិច្ឆេទនៃការចាប់ខ្លួន |

| សេចក្តីលម្អិតនៃការកែតម្រូវ៖ |
|---|
| សូមមើលការផ្លាស់ប្តូរ កថាខណ្ឌ២ និងជើងទំព័រ៣ |

ស្នើដោយ៖ក្រឡាបញ្ជី ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ ហត្ថលេខា៖

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / 03 / 2013
ម៉ោង (Time/Heures): 13 : 40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# ១. សេចក្តីផ្តើម

១ អង្គជំនុំជម្រះសាលាដំបូងបានទទួលលិខិតបញ្ជាក់មរណភាពរបស់ជនជាប់ចោទ អៀង សារី ពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣[1]។

# ២. ប្រវត្តិនីតិវិធី

២ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរចោទប្រកាន់ នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ និង កាំង ហ្គេកអ៊ាវ ហៅឌុច បានប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[2]។ នៅថ្ងៃទី ~~១៤~~១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ជនជាប់ចោទ អៀង សារី ត្រូវបានចាប់ខ្លួនដោយដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត និងបានបញ្ជូនមកមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ហើយបានជូនដំណឹងពីបទចោទប្រឆាំងនឹងជនជាប់ចោទរូបនេះ[3]។ នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចោទប្រកាន់ប្រឆាំងនឹង អៀង សារី នួន ជា ខៀវ សំផន អៀង ធីរិទ្ធ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការបំពានបំពាន ធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[4]។ នៅក្នុងការសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានតម្កល់ទុកជាបានការ ដោយមានការសម្រេចកែប្រែផ្នែកខ្លះនៃដីកាដំណោះស្រាយ

---

[1] លិខិតមរណភាពរបស់ អៀង សារី, ឯកសារ E270, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, ឯកសារ D3, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧។ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានបំបែកនៅពេលក្រោយមកទៀត (ដីកាបំបែកសំណុំរឿង, ឯកសារ D18, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧)។

[3] ដីកាបង្គាប់ឲ្យឃុំខ្លួន អៀង សារី, ឯកសារ C23, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧; ដីកាដំណោះស្រាយ, ឯកសារ D427, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ"), កថាខណ្ឌ ៧។, សេចក្តីសម្រេចឃុំខ្លួន, ឯកសារ C14, ថ្ងៃទី ១២ វិច្ឆិកា ២០០៧។

[4] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៦១៣។ សហចៅក្រមស៊ើបអង្កេតក៏បានចោទប្រកាន់ជនជាប់ចោទចំពោះការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ នៅពេលក្រោយមកទៀត អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាដីកាដំណោះស្រាយបានខកខានពុំបានបញ្ជាក់អំពីការចោទប្រកាន់ទាំងនេះឲ្យបានជាក់លាក់គ្រប់គ្រាន់ និងបានណែនាំថាការចោទប្រកាន់ទាំងនេះពុំមែនជាមូលដ្ឋាននៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះទៅថ្ងៃមុខក្នុងសំណុំរឿង00២ឡើយ (សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ), ឯកសារ E122, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១)។